Cambodian Farmer Federation
Association of Agricultural Producers
CFAP-CAMBODIA

# បច្ចេកទេសដាំដុះពូជដំណាំស្រូវ

# Technical Rice Seed Planting



## មាតិកា

១. ការជ្រើសរើសពូជ ....................................................................................................4
១.១ ការធ្វើដំណុះសាក ....................................................................................................4
១.២ ការជ្រើសរើសគ្រាប់ពេញយកទៅព្រោះ ....................................................................................................5
១.៣ គុណសម្បត្តិនៃការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ និងគុណភាពល្អ ....................................................................................................5
២. បច្ចេកទេសដាំដុះ ....................................................................................................6
២.១ ការរៀបចំដីស្រែ....................................................................................................6
២.២ ការភ្ជួររាស់ដីស្រែ ....................................................................................................6
៣. វិធីសាស្រ្តព្រោះស្រូវ ....................................................................................................7
៣.១ ការព្រោះគ្រាប់ស្រូវស្ងួតលើដីស្ងួត:....................................................................................................7
៣.២ ការព្រោះគ្រាប់ស្រូវដែលបណ្ដុះរួចលើដីសើម:....................................................................................................7
៣.៣ ការព្រោះស្រូវសើមនៅក្នុងទឹក: ....................................................................................................8
៤. ការគ្រប់គ្រងជីជាតិដី....................................................................................................8
៤.១ ដីប្រទះឡាង....................................................................................................9
៤.២ ដីគោកគ្រប់....................................................................................................9
៥. ការប្រើប្រាស់ជី ....................................................................................................9
៥.១ បរិមាណ និងពេលវេលានៃការប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវ....................................................................................................9
៥.២ បរិមាណ និងពេលវេលានៃការប្រើប្រាស់ជីបំប៉នលើដំណាំស្រូវ ....................................................................................................10
៦. ការគ្រប់គ្រងទឹក ....................................................................................................11
៦.១ អត្ថប្រយោជន៍នៃការគ្រប់គ្រងទឹកបានល្អ ....................................................................................................11
៧. វិធានការគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ....................................................................................................11
៧.១ ស្មៅចង្រៃ ....................................................................................................11
៧.២ ជំងឺលើដំណាំស្រូវ....................................................................................................12

៨. សត្វល្អិតក្នុងប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ....14
៨.១ ប្រភេទសត្វចង្រៃសំខាន់ៗ និងវិធានការកំចាត់....14
៩. ការប្រមូលផល....16
១០. ការគ្រប់គ្រងគ្រោះហានិភ័យនានាចំពោះដំណាំស្រូវពង្រោះ....17
១១. ការធ្វើផែនការផលិតកម្ម....18
១១.១ ការកត់ត្រាចំណាយ ចំណូលផលិតកម្ម....18
១១.២ តារាងគំរូ សម្រាប់វិភាគចំណាយ ចំណូលផលិតកម្មដំណាំស្រូវ....19
១១.៣ គំរូផលិតកម្មដំណាំស្រូវដោយផ្អែកលើការសិក្សានៃសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (សម្រាប់ផ្ទៃដី ០.៥០ហត)។ អាចមានការប្រែប្រួលទៅតាមការជាក់ស្តែង។....20

## ១. ការជ្រើសរើសពូជ

ពូជនិងគ្រាប់ពូជដើរតួ យ៉ាងសំខាន់ក្នុងផលិតកម្មដំណាំស្រូវ។ គ្រាប់ពូជជាអ្នកផ្ទុកនិងបញ្ជូនព័ត៌មានសេនេទិច ទៅរុក្ខជាតិជំនាន់ក្រោយ មានន័យថា បើយើងដាំពូជស្រូវក្រអូប យើងនឹងទទួលបានស្រូវក្រអូប បើយើងដាំពូជស្រូវដំណើប យើងនឹងទទួលបានស្រូវដំណើប។ ពូជស្រូវមានច្រើនប្រភេទ ហើយខុសគ្នាតាមរដូវកាល (ប្រកាន់រដូវ និងមិនប្រកាន់រដូវ) អាយុកាល (ស្រូវស្រាល កណ្តាល ធ្ងន់) រសជាតិអង្ករ និងក្លិន។ ដូច្នេះកសិករត្រូវជ្រើសរើសពូជដែលផ្តល់ទិន្នផលខ្ពស់ ធន់នឹងកត្តាចង្រៃ ស្របនឹងប្រព័ន្ធក្សេត្របរិស្ថាន និងតម្រូវការទីផ្សារមកធ្វើការដាំដុះ។ កសិករគួរប្រើប្រាស់ពូជតាមការណែនាំរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដូចខាងក្រោម៖

- ប្រើពូជស្រូវអ៊ីរ៉ែអ៊ែរ ៦៦ (IR 66) សែនពិដោរ និងជលសារ ជាពូជស្រូវស្រាលមិនប្រកាន់រដូវ ហើយផ្តល់ទិន្នផលខ្ពស់សមស្រប សម្រាប់លក្ខខណ្ឌស្រូវបង្កើនរដូវ និងស្រូវប្រាំង ឬ ស្រូវវស្សាក្នុងលក្ខខណ្ឌស្រែទួល ឬ ស្រែលើ មិនសូវដក់ទឹក ។
- ប្រើពូជស្រូវផ្ការំដួល ផ្ការំដេង ផ្ការមៀត ផ្កាចន្ទន៍សែនសរ ជាពូជស្រូវកណ្តាល ប្រកាន់រដូវមានរសជាតិឆ្ងាញ់ និងមានតម្លៃខ្ពស់នៅលើទីផ្សារ និងសមស្របសម្រាប់លក្ខខណ្ឌស្រែលើ។
- ពូជស្រូវរាំងជ័យ ខា៤ ខា៦ ជាពូជស្រូវធ្ងន់ប្រកាន់រដូវ សមស្របសម្រាប់ស្រែជម្រៅ។

ត្រូវចងចាំថាពូជស្រូវសែនពិដោរ ផ្ការំដួល ផ្ការំដេង ផ្ការមៀត ជាពូជស្រូវប្រណិត ដែលមានក្លិនក្រអូប និងមានតម្លៃខ្ពស់នៅលើទីផ្សារ ។

ប្រើគ្រាប់ពូជសម្រាប់ប្រើប្រាស់ក្នុងផលិតកម្មត្រូវតែជាពូជសុទ្ធល្អ និងមានដំណុះចាប់ពី ៨៥% ឡើងទៅ ពោលគឺជាគ្រាប់ពូជបានមកពីការសម្រិតសម្រាំងយ៉ាងត្រឹមត្រូវ។

### ១.១ ការធ្វើដំណុះសាក

ដើម្បីកំណត់នូវបរិមាណពូជដែលត្រូវយកទៅព្រោះឱ្យបានសមស្រប ការធ្វើដំណុះគ្រាប់សាកល្បងគឺជាការងារសំខាន់បំផុត។ ជាទូទៅគ្រាប់ពូជដែលមានដំណុះល្អ ស្ថិតក្នុងចន្លោះពី ៣ខែ ទៅ ១០ខែ ក្រោយពេលប្រមូលផល។ ស្ថិតក្នុងលក្ខខណ្ឌធម្មតា ក្រោយពេលប្រមូលផលពី ១-២ ខែគ្រាប់ពូជភាគច្រើនស្ថិតក្នុងដំណេក (មិនសូវដុះ) ហើយបើទុកយូរលើសពី ១០ខែ កន្លះឡើងទៅ ដំណុះគ្រាប់នឹងត្រូវធ្លាក់ចុះជាបន្តបន្ទាប់។ មានវិធីសាស្ត្រផ្សេងៗជាច្រើនសម្រាប់ធ្វើដំណុះសាក ហើយវិធីសាស្ត្រងាយៗសម្រាប់ធ្វើដំណុះសាកមានដូចខាងក្រោម៖

- ជ្រើសរើសយកគ្រាប់ដោយចៃដន្យចំនួន ៣កន្លែង ពីបាវស្រូវនីមួយៗពីផ្នែកខាង លើ កណ្តាល និង ផ្នែកខាងក្រោម នៃបាវស្រូវ រួចប្របល់ចូលគ្នា។ ហើយចាប់យក ១០០គ្រាប់ ដោយចៃដន្យទាំងគ្រាប់ល្អ និងមិនល្អ ដោយអនុវត្តឱ្យបាន ៣-៥ សំណាក ។
- ដាក់គ្រាប់ស្រូវដែលរាប់ចូលក្នុងចាន ឬ កែវ ចាក់ទឹកចូលរហូតដល់លិចពីលើគ្រាប់ពូជកម្ពស់ប្រមាណ ៣ស.ម កូរគ្រាប់ឱ្យបានសព្វរួចគ្រប និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព។
- រយៈពេល៣ថ្ងៃ យើងអាចរាប់ចំនួនគ្រាប់ដុះ និងគ្រាប់មិនដុះសរុប គឺជាអត្រាដំណុះគ្រាប់ពូជ។តាមលទ្ធផលនៃដំណុះសាក និងកម្រិតគ្រាប់ពូជដែលចាំបាច់ត្រូវប្រើ យើងអាចគណនាបរិមាណគ្រាប់ពូជដែលសមស្រប សម្រាប់យកទៅសាបបានយ៉ាងងាយ។

## ១.២ ការជ្រើសរើសគ្រាប់ពេញយកនៅព្រោះ

ប្រសិនបើយើងសង្កេតឃើញថាគ្រាប់ពូជមានដំណុះទាប ដោយសារការមានលាយសំដីច្រើន(គ្រាប់ស្កៀត) យើងអាចធ្វើការជ្រើសរើសគ្រាប់ដែលល្អយកទៅព្រោះ ដោយគ្រាន់តែចាក់គ្រាប់ពូជចូលទៅក្នុងធុងទឹក រួចចាក់ទឹកចូលឱ្យជិតពេញធុងរួចកូរឱ្យសព្វ បន្ទាប់មកស្រង់គ្រាប់ដែលអណ្តែតលើផ្ទៃទឹកចេញ។ ចំណែកគ្រាប់លិចទឹកត្រូវចាក់ទុកមួយកន្លែង រួចបន្តធ្វើការជ្រើសរើសតាមវិធីនេះរហូតដល់អស់គ្រាប់ពូជដែលត្រូវយកទៅព្រោះ។

## ១.៣ គុណសម្បត្តិនៃការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ និងគុណភាពល្អ

- មានសារធាតុបម្រុងគ្រប់គ្រាន់ សម្រាប់ឱ្យសំណាបលូតលាស់ និងមានសុខភាពល្អ
- ធ្វើឱ្យដើមស្រូវដុះលូតលាស់បានស្មើគ្នាល្អ
- ភោគផលស្រូវដែលផលិតបានមានគុណភាពល្អ ងាយស្រួលរកទីផ្សារ និងមានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិ
- គុណភាពអង្ករ រក្សាបាននូវភាពដើមទាំងរសជាតិ និងក្លិន
- គ្រាប់ពូជសុទ្ធល្អ និងមានគុណភាពខ្ពស់ អាចជួយឱ្យទិន្នផលស្រូវកើនឡើងពី ១៥-២០% ។

## ២. បច្ចេកទេសដាំដុះ

### ២.១ ការរៀបចំដីស្រែ

ការរៀបចំដីស្រែ មានឥទ្ធិពលយ៉ាងខ្លាំងលើការលូតលាស់របស់ដំណាំស្រូវ។ ការរៀបចំដីបានល្អគឺធ្វើឱ្យដីស្រែផុសនិងមានរន្ធខ្យល់ច្រើនដែលអាចជួយសម្រួលដល់ការលូតលាស់របស់ប្រព័ន្ធឬសបង្កើនជីជាតិដីតាមរយៈការភ្ជួរលុបស្មៅ និងគល់ជញ្ជ្រាំង ងាយស្រួលក្នុងការគ្រប់គ្រងទឹក និងស្មៅចង្រៃ ជាពិសេស អាចសម្លាប់ពពួកផ្សិត សម្លាប់ពងដឹកដឿ និងសត្វល្អិតផងដែរ។ ជាកាល្អប្រសើរកសិករត្រូវភ្ជួរដាស់ដីស្រែនៅពេលមានភ្លៀងធ្លាក់សើមល្មម ភ្ជួរដើម្បីសម្លាប់ស្មៅ សម្លាប់ភ្នាក់ងារបង្កជំងឺ និងបំផ្លាញពង ឬ ដឹកដឿសត្វល្អិត ហើយធ្វើឱ្យដីផុសល្អមានរន្ធខ្យល់ចេញចូលល្អ ដែលបង្កលក្ខខណ្ឌល្អប្រសើរសម្រាប់ការដុះលូតលាស់របស់ដំណាំស្រូវ ។

ត្រូវចងចាំថា ការរៀបចំដីស្រែមិនបានល្អ ពោលគឺភ្ជួរមិនបានសព្វ រាស់ដីមិនបានម៉ដ្ឋល្អ និងកៀរដីមិនស្មើធ្វើឱ្យស្រូវពិបាកចាក់ឬស ពីព្រោះដីរឹង និងដុះស្មៅច្រើនដោយសារដីទាបខ្ពស់ និងការចែកចាយទឹក និងជីមិនបានស្មើល្អធ្វើឱ្យស្រូវដុះលូតលាស់មិនស្មើល្អ និងទទួលបានទិន្នផលទាប ។

### ២.២ ការភ្ជួររាស់ដីស្រែ

- ការភ្ជួរដីលើកទី១៖ ត្រូវចាប់ផ្ដើមនៅពេលច្រូតកាត់ហើយភ្លាមៗ ព្រោះដីនៅមានសំណើមសមស្រប។
- ការភ្ជួរដីលើកទី២៖ អាចធ្វើឡើងនៅមុនពេលព្រោះស្រូវចំនួន ១-២ សប្ដាហ៍ ដើម្បីឱ្យស្មៅរលួយ។ ជម្រៅនៃការភ្ជួររាស់គឺមានការប្រែប្រួលទៅតាមប្រភេទដីដូចជា ប្រភេទដីខ្សាច់ត្រូវភ្ជួរជម្រៅពី ៨-១២ ស.ម និងដីល្បាយឥដ្ឋភ្ជួរជម្រៅពី ១៥-២៥ ស.ម និងរាស់ឱ្យបាន១ដង និងកៀរពង្រាបដីឱ្យបានស្មើល្អ។ បន្ទាប់មក ត្រូវជីកជាចង្អូរៗនៅក្នុងស្រែពង្រោះ ដែលចង្អូរនីមួយៗគួរមានប្រវែងចាប់ពី ៤-៥ ម៉ែត្រ។ ការជីកជាចង្អូរនេះ ដើម្បីងាយស្រួលក្នុងការបង្ហូរទឹកចេញ ចូល ងាយស្រួលក្នុងការដើរព្រោះស្រូវ ងាយស្រួលក្នុងការបាចជីបំប៉ន និងងាយស្រួលក្នុងការថែទាំដំណាំស្រូវ។




## ៣. វិធីសាស្ត្រព្រោះស្រូវ

វីធីសាស្ត្រព្រោះស្រូវចម្បងៗ ដែលកសិករនិយមប្រើប្រាស់រួមមាន ៣ ប្រភេទគឺ៖

**៣.១ ការព្រោះគ្រាប់ស្រូវស្ងួតលើដីស្ងួត:** ក្រោយពីរៀបចំដីរួចរាល់កសិករយកគ្រាប់ស្រូវស្ងួតទៅព្រោះលើដីស្រែស្ងួតដែលគ្មានទឹក ហើយរង់ចាំទឹកភ្លៀងធ្លាក់។ ប៉ុន្តែចំពោះស្រែដែលមានប្រព័ន្ធធារាសាស្ត្រ ឬ មានប្រភពទឹក កសិករអាចបូមទឹកបញ្ចូលក្នុងស្រែ ដើម្បីឱ្យគ្រាប់ស្រូវដុះបានល្អ។




**៣.២ ការព្រោះគ្រាប់ស្រូវដែលបណ្ដុះរួចលើដីសើម:** ក្រោយពីភ្ជួររាស់ កៀរពង្រាបដីរួច កសិករយកគ្រាប់ពូជដែលដុះពន្លក (ត្រាំទឹក ១២ ម៉ោង និងផ្អាប់ ២៤ ម៉ោង) ទៅព្រោះលើដីសើមភក់ល្បាប់មានទឹកតិចៗ។

**៣.៣ ការព្រោះស្រូវសើមនៅក្នុងទឹក:** កសិករបានរៀបចំដីរួចជាស្រេចមុនពេលទឹកឡើងខ្លាំង ហើយនៅពេលទឹកស្រកទៅវិញនៅសល់កម្ពស់ប្រមាណ ២០-៣០ ស.ម កសិករយកគ្រាប់ពូជស្រូវដែលសើមទៅព្រោះលើស្រែតែម្តង។ ការព្រោះក្នុងទឹកនេះអាចចំណេញការបញ្ចូលទឹក ហើយស្រូវខ្លះអាចដុះប្រជែងឈ្នះស្មៅ (ដុះមុនស្មៅ) ប៉ុន្តែអាចមានការបំផ្លាញពន្លកស្រូវដោយសារត្រី និងសត្វក្នុងទឹកផ្សេងៗទៀត ។

***<u>ចំពោះការប្រើប្រាស់ពូជស្រូវមានដូចជា:</u>***

- ស្រូវស្រាល: ប្រើប្រាស់គ្រាប់ពូជចាប់ពី ១០០-១២០ គីឡូក្រាម/ហិកតា
- ស្រូវកណ្តាល: ប្រើប្រាស់គ្រាប់ពូជចាប់ពី ៨០-១០០ គីឡូក្រាម/ហិកតា
- ស្រូវធ្ងន់: ប្រាស់គ្រាប់ពូជចាប់ពី ៦០-៨០ គីឡូក្រាម/ហិកតា

❖ ការព្រោះស្រូវបានល្អត្រឹមត្រូវតាមបច្ចេកទេសមានអត្ថប្រយោជន៍ដូចជា:

- ចំណេញគ្រាប់ពូជ ចំណេញថវិកា
- ស្រូវដុះលូតលាស់ល្អ
- មិនដុះស្មោកពេក មានខ្យល់ចេញចូលបានគ្រប់គ្រាន់ និងស្រូបយកពន្លឺថ្ងៃបានគ្រប់គ្រាន់
- ងាយស្រួលក្នុងការថែទាំ
- ទទួលបានទិន្នផលខ្ពស់ ។

## ៤. ការគ្រប់គ្រងជីជាតិដី

ការគ្រប់គ្រងជីជាតិដី បានត្រឹមត្រូវ និងធានាបាននូវនិរន្តរភាពផលិតកម្ម ប្រសិទ្ធភាពសេដ្ឋកិច្ច និងតុល្យភាពប្រព័ន្ធបរិស្ថាន។ ជារៀងរាល់រដូវស្រូវបានស្រូបយកសារធាតុចិញ្ចឹមដូចជា អាសូត ផូស្វ័រ ប៉ូតាស្យូម និងសារធាតុមួយចំនួនទៀតពីក្នុងដី។ ប្រសិនបើយើងមិនបានបំពេញសារធាតុចិញ្ចឹមទាំងនោះទៅដល់ដីទេ នាំឱ្យដីខាតបង់ជីជាតិជាប្រចាំ ហើយលទ្ធផលធ្វើឱ្យដំណាំស្រូវដុះលូតលាស់មិនបានល្អ និងទទួលបានទិន្នផលកាន់តែទាបជាងមុន។ ដូច្នេះការគ្រប់គ្រងជីជាតិដី គឺជាកត្តាមួយសំខាន់បំផុតសម្រាប់ដំណាំស្រូវ។ ការបើប្រាស់ជីទៅលើដំណាំ ស្រូវមានការប្រែប្រួលទៅតាមប្រភេទដី។ លក្ខណ:សម្គាល់ និងបទដ្ឋានៃការប្រើប្រាស់ជី ទៅតាមប្រភេទដី នៃបណ្តាខេត្ត ស្រុកនៅកម្ពុជា។ ដោយឡែកដីសម្រាប់ដាំដំណាំស្រូវនៅខេត្តស្វាយរៀង មានដីសម្រាប់ដាំដុះដំណាំ ស្រូវ ២ ប្រភេទដូចខាងក្រោម:

### ៤.១ ដីប្រទះឡាង

- ***កំណកំណើតដី:*** ល្បាប់ជំនាន់ចាស់ ឬល្បាប់សំណើក (ជំនន់) ស្រទាប់លើជាដីខ្សាច់មានជម្រៅតិចជាង ៤០ ស.ម ស្រទាប់ក្រោមជាដីល្បាយ ឬ ដីឥដ្ឋ ។
- ***ការប្រើប្រាស់ដី:*** ដីអ៊ុយរ៉េ: ៥០-៨៧.៥ គ.ក្រ/ហិកតា, ដី ដេអាប៉េ: ៥០-៨៨ គ.ក្រ/ហិកតា, ដី ប៉ូតាស ៥០ គ.ក្រ/ហិកតា ។

### ៤.២ ដីតោកត្រប់

- ***កំណកំណើតដី:*** ល្បាប់ជំនាន់ចាស់ ដីស្ងួតពណ៌ប្រផេះ ទៅប្រផេះស្រអាប់ ហើយស្រទាប់លើជាល្បាយ ឬ ដីឥដ្ឋ អាស៊ីតខ្លាំង។
- ***ការប្រើប្រាស់ដី:*** អ៊ុយរ៉េ: ៦៧-១២០ គ.ក្រ/ហិកតា, ដី ដេអាប៉េ: ៥០-៦១ គ.ក្រ/ហិកតា, ដី ប៉ូតាស ៥០ គ.ក្រ/ហិកតា ។

## ៥. ការប្រើប្រាស់ជី

ទោះបីជាមានប្រភេទដីខុសៗគ្នាយ៉ាងណាក៏ដោយ តែការប្រើប្រាសើជីមិនមានភាពខុសគ្នានោះទេ គឺត្រូវអនុវត្តវិធានការចម្រុះគ្រប់គ្រងជីជាតិដី តាមរយៈការប្រើបរិមាណជីសមស្របតាមតម្រូវការ និងវគ្គលូតលាស់របស់ដំណាំមានជីធម្មជាតិ (ជីសរីរាង្គ) និងជីគីមី។ ជីធម្មជាតិរួមមាន: ជីកំប៉ុស្តិ៍ ជីលាមកសត្វ កាកសំណល់រុក្ខជាតិ ជីកាកសំណល់ឡជីវឧស្ម័ន និងជីស្រស់។ ជាការចាំបាច់ កសិករត្រូវមានរោងសន្សំជីកំប៉ុស្តិ៍ នៅតាមផ្ទះនីមួយៗដែលអាចផ្សំពីលាមកសត្វ ទឹកនោមសត្វ កាកសំណល់ផ្ទះបាយ កាកសំណល់រុក្ខជាតិ ដែលនេះជារោងចក្រផលិតជីធម្មជាតិតាមគ្រួសារ ដោយចំណាយអស់ទុនតិច ប៉ុន្តែទទួលបានផលច្រើន។ ជីធម្មជាតិដែលទទួលបានពីឡជីវឧស្ម័នគឺមានគុណភាពល្អ និងបានសម្លាប់មេរោគបង្កជំងឺ និងគ្រាប់ស្មៅដែលឆ្លងរាលដាលដល់ដំណាំស្រូវ ។

### ៥.១ បរិមាណ និងពេលវេលានៃការប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវ

ការប្រើប្រាស់ជីទ្រាប់បាតពិតជាមានសារៈសំខាន់ណាស់ចំពោះស្រូវ។ ខាងក្រោមនេះ ជាបរិមាណ ជី និង ពេលវេលា ដែលកសិករអាចប្រើប្រាស់ជីទ្រាប់បាតលើដំណាំស្រូវមានដូចជា:

- **<u>ជីកំប៉ុស្តិ៍</u>**៖ ប្រើប្រាស់ជាជីទ្រាប់បាត ចំនួន ១០-១៥ តោន/ហិកតា ដោយភ្ជួរលុបភ្លាមក្រោយពេលដាក់ជីរួច ដើម្បីចៀសវាងការបាត់បង់សារធាតុចិញ្ចឹម ។

- ជីធម្មជាតិ (ក្រុមហ៊ុននានា) ប្រើប្រាស់ជាជីទ្រាប់បាត ចំនួន ២០០ គ.ក្រ/ហិកតា (ចំនួន៤បាវ) ។ ដោយជីធម្មជាតិ(ក្រុមហ៊ុន) ៥០ គ.ក្រត្រូវប្រើជាមួយជី អ៊ុយរ៉េ ចំនួន ៥ គ.ក្រ។ ***របៀបប្រើប្រាស់ជី:*** នៅពេលភ្ជួររួចហើយ ត្រូវបាចជីរួចរាស់កប់។ ម្យ៉ាងទៀតគេអាចប្រើប្រាស់ជី ១៥-១៥-១៥ ចំនួន ១០០-១៥០ គ.ក្រ/ហិកតា។ ***របៀបប្រើប្រាស់ជី:*** នៅពេលភ្ជួររួចហើយ ត្រូវបាចជី រួចរាស់កប់។

## ៥.២ បរិមាណ និងពេលវេលានៃការប្រើប្រាស់ជីបំប៉នលើដំណាំស្រូវ

- **ជីបំប៉នលើកទី១៖** បាចជីអ៊ុយរ៉េ ចំនួន ៥០ គ.ក្រ/ហិកតា (បាចជីក្រោយព្រោះ ៣០ថ្ងៃ)
- **ជីបំប៉នលើកទី២៖** បាចជីអ៊ុយរ៉េ ចំនួន ៣៥-៤០ គ.ក្រ/ហិកតា (បាចជីមុនពេលស្រូវផើម) ។

➢ ***សំគាល់:*** ការបាចជីបំប៉នគួរធ្វើឡើងនៅពេលព្រឹកព្រលឹម ពេលថ្ងៃរះ គឺនៅពេលអស់ទឹកសន្សើមលើស្លឹកស្រូវ និងនៅពេលល្ងាចចន្លោះពីម៉ោង ៤-៥ រសៀល គឺនៅពេលអាកាសធាតុត្រជាក់ល្មម ។ ការបាចជីនៅពេលព្រឹក ធ្វើឱ្យដំណាំស្រូវមានរយៈពេលគ្រប់គ្រាប់សម្រាប់ស្រូបសារធាតុចិញ្ចឹម។ ត្រូវបាចជីបំប៉នដំណាំស្រូវនៅមុនពេលស្រូវចាប់ផ្តើមករកើតកួរ។ កាលណាយើងបាចជីដល់ដំណាក់កាលស្រូវករកើតកួរដំណាំស្រូវមិនអាចចាប់យកជីបានទេ ប្រៀបដូចជាបាចលុយចោល នាំឱ្យខាតបង់ថវិកា។

**រូបភាព: ការបាចជីបំប៉នលើដំណាំស្រូវ**





## ៦. ការគ្រប់គ្រងទឹក

ទឹក ជាធនធានចាំបាច់សម្រាប់ផលិតកម្មដំណាំស្រូវ។ ទឹកដើរតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការលូតលាស់របស់ដំណាំស្រូវធ្វើឱ្យរុក្ខជាតិធន់នឹងកម្តៅ។ តម្រូវការទឹករបស់ដំណាំស្រូវអាស្រ័យទៅតាមដំណាក់កាលលូតលាស់របស់វាដូចជា៖

- ដំណាក់កាលលូតលាស់: តម្រូវការទឹកកម្ពស់ពី ១-៣ ស.ម
- ដំណាក់កាលបង្កើនផល: តម្រូវការទឹកកម្ពស់ពី ៣-៥ ស.ម
- ដំណាក់កាលទុំ: តម្រូវការទឹកកម្ពស់ពី ២-៣ ស.ម។ នៅក្នុងដំណាក់កាលនេះ មិនត្រូវឱ្យមានទឹកក្នុងស្រែច្រើនពេកទេ។ នៅពេលស្រូវដាក់ម្សៅ ស្រូវចាប់ផ្តើមក្រហមចុងក្ួរត្រូវបង្ហូរទឹកចេញពីក្នុងស្រែ ដើម្បីឱ្យស្រូវទុំលឿន ឆាប់ទុំ ទុំស្រុះគ្នា ទុំដំណាលគ្នា ។

### ៦.១ អត្ថប្រយោជន៍នៃការគ្រប់គ្រងទឹកបានល្អ

- កសិករចំណេញថវិកា ដែលត្រូវចំណាយក្នុងការស្រោចស្រព
- កាត់បន្ថយការចំណាយលើការធ្វើស្មៅ
- ដំណាំស្រូវដុះលូតលាស់ល្អ បែកគុម្ពច្រើន និងផ្តល់ទិន្នផលខ្ពស់
- កាត់បន្ថយហានិភ័យក្នុងការខ្វះទឹក ដែលអាចធ្វើឱ្យស្រូវងាប់ ឬ ស្គក ។

## ៧. វិធានការគ្រប់គ្រងសមាសភាពចង្រៃលើដំណាំស្រូវ

សមាសភាពចង្រៃ របស់ដំណាំស្រូវរួមមាន៖ ស្មៅចង្រៃ សត្វល្អិតចង្រៃ និងជំងឺបំផ្លាញដំណាំ ។

### ៧.១ ស្មៅចង្រៃ

ស្មៅចង្រៃ គឺជាប្រភេទរុក្ខជាតិទាំងឡាយណាដែលដុះនៅក្នុងស្រែ ហើយប្រកួតប្រជែងដល់ការលូតលាស់របស់ដំណាំស្រូវ ។ ស្មៅចង្រៃ ចែកចេញជា ៣ប្រភេទ ពពួកស្មៅស្លឹកតូច ស្មៅស្លឹកធំ និងពពួកកក់។ ក្នុងចំណោមស្មៅទាំង ៣ ប្រភេទខាងលើនេះ ស្មៅស្លឹកតូចដណ្តើមជីជាតិពីស្រូវខ្លាំងជាងគេ ។

***ក. វិធានការគ្រប់គ្រង និងកំចាត់ស្មៅចង្រៃ***

ដើម្បីគ្រប់គ្រង និងកំចាត់ស្មៅចង្រៃ ប្រកបដោយប្រសិទ្ធិភាព កសិករគួរអនុវត្តនូវវិធានការមួយចំនួនដូចខាងក្រោម:

- ត្រូវភ្ជួររាស់ដី នៅពេលមានសំណើមគ្រប់គ្រាន់
- ត្រូវសំអាតគ្រាប់ពូជស្រូវឱ្យបានស្អាតអស់គ្រាប់ស្មៅចង្រៃជាមុនសិន
- រៀបចំដីស្រែឱ្យបានស្អាត និងរាបស្មើ
- ធ្វើស្មៅបំផុសដីឱ្យបានយ៉ាងតិច ២ ដង ដោយដៃ ឬ ឧបករណ៍ធ្វើស្មៅ
- ចំពោះការប្រើប្រាស់ថ្នាំកសិកម្ម: គឺគួរប្រើនៅមុនពេលភ្ជួរដី ប្រហែលជា ៥-៧ ថ្ងៃមុនពេលភ្ជួរ។ មិនត្រូវប្រើប្រាស់ថ្នាំសម្លាប់ស្មៅនៅពេលដែលព្រោះស្រូវរួចហើយទេ វាអាចធ្វើឱ្យអន់ដំណាំស្រូវលូតលាស់យឺត។

## ៧.២ ជំងឺលើដំណាំស្រូវ

ជំងឺ គឺជាដំណើរមិនប្រក្រតីមួយដែលធ្វើឱ្យរុក្ខជាតិមានរបួស ឬ ជាដំណើរមិនប្រក្រតីនៃប្រតិកម្មគីមីជីវៈ ដែលធ្វើឱ្យមានដំណើរការខុសធម្មតា។ ភ្នាក់ងារបង្កជំងឺមានដូចជា: វីរុស បាក់តេរី ផ្សិត និងណេម៉ាតូត។

### *ក. វិធានការទប់ស្កាត់ និងកំចាត់ជំងឺស្រូវ*

ជាទូទៅ ជំងឺដែលមានការលូតលាស់យឺត ងាយស្រួលគ្រប់គ្រងជាងជំងឺដែលលូតលាស់ឆាប់រហ័ស ហើយជាការលំបាកណាស់ក្នុងការគ្រប់គ្រងជំងឺ ដែលមានការឆ្លងរាលដាលលឿន។

➢ ***វិធានការបង្ការ និងកម្ចាត់ជំងឺបង្កឡើងដោយពពួកផ្សិត***

ជំងឺ ដែលបង្កឡើងដោយពពួកផ្សិតលើដំណាំស្រូវមានដូចជា: ជំងឺអុចត្នោត ជំងឺប្លាស ជំងឺរលាកស្រទបស្លឹក និងជំងឺរលួយស្រទបស្លឹក ។ល។

- ត្រូវរៀបចំដីឱ្យបានល្អ (ភ្ជួររាស់ឱ្យបានសព្វល្អ) និងហាលដីឱ្យបានស្ងួតដើម្បីសម្លាប់ផ្សិត
- ប្រើប្រាស់គ្រាប់ពូជដែលធន់ទ្រាំនឹងជំងឺ និងគ្មានកើតជំងឺ
- សម្លាប់មេរោគផ្សិតលើគ្រាប់ពូជ មុននឹងយកទៅព្រោះដោយហាលនឹងកម្តៅថ្ងៃ ឬត្រាំទឹកក្តៅឧណ្ហៗ ឬ ប្រើថ្នាំផ្សិត
- ប្រមូល និងដុតចោលកាកសំណល់រុក្ខជាតិដែលកើតជំងឺ
- កម្ចាត់ស្មៅ និងរុក្ខជាតិដែលជាជម្រកជំងឺ និងភ្នាក់ងារចម្លង
- ចៀសវាងការប្រើប្រាស់ជីអាសូតច្រើន ដែលជំរុញការលូតលាស់លើសកម្រិត
- ប្រើប្រាស់ថ្នាំសម្លាប់ផ្សិត ត្រឹមត្រូវតាមបច្ចេកទេស
- ធ្វើអនាម័យស្រែក្រោយពេលប្រមូលផលអស់



➢ ***វិធានការបង្ការ និងកម្ចាត់ជំងឺបង្កឡើងដោយបាក់តេរី***

ជំងឺ ដែលបង្កឡើងដោយបាក់តេរីលើដំណាំស្រូវមានដូចជាៈ ជំងឺស្រពោនស្លឹក ជំងឺឆ្នូតស្លឹក................។ល។

- ប្រើប្រាស់ពូជធន់នឹងបាក់តេរី ពូជគ្មានជំងឺ
- ការដាំដំណាំឆ្លាស់
- ការធ្វើអនាម័យស្រែ
- ការប្រើប្រាស់ថ្នាំកសិកម្ម

➢ ***វិធានការបង្ការ និងកម្ចាត់ជំងឺបង្កឡើងដោយបាក់តេរី***

ជំងឺ ដែលបង្កឡើងដោយបាក់តេរីមានដូចជាៈ ជំងឺតឿស្មៅ ជំងឺតឿរួញស្លឹក ជំងឺទុងគ្រោ...................។ល។

- ប្រើប្រាស់ពូជដែលធន់ទ្រាំទៅនឹងជំងឺ
- ប្រើប្រាស់គ្រាប់ពូជដែលមិនមានផ្ទុកជំងឺវីរុស

- កម្ចាត់ភ្នាក់ងារចម្លង ជាពិសេសពពួកមមាច និងសត្វស៊ីស្រូវដែលមានប្រអប់មាត់ជញ្ជក់ផ្សេងទៀត
- ប្រមូល និងដុតចោលនូវដើមស្រូវដែលទទួលការបំផ្លាញពីជំងឺវីរុស ។

# ៨. សត្វល្អិតក្នុងប្រព័ន្ធអេកូឡូស៊ីស្រែស្រូវ

## ៨.១ ប្រភេទសត្វចង្រៃសំខាន់ៗ និងវិធានការកំចាត់

សត្វល្អិតសំខាន់ៗបំផ្លាញដំណាំស្រូវ រួមមាន: ទ្រីប មមាចត្នោត ដង្កូវបំពង់កាត់ស្លឹក ដង្កូវស៊ីរូងដើម ដង្កូវមូរស្លឹក ស្រឹងជញ្ជក់ទឹកដោះ សង្កើចខ្មៅ ខ្យងពណ៌មាស និងកណ្ដុរ។

***ក. ទ្រីប:*** ជាសត្វល្អិតតូចៗពណ៌ខ្មៅ បំផ្លាញដំណាំស្រូវនៅក្នុងវគ្គលូតលាស់ ជាពិសេស បំផ្លាញលើសំណាប។ ស្លឹកដែលរងការបំផ្លាញរមូរស្ងួតប្រែជាពណ៌ត្នោត និងអាចបណ្ដាលឱ្យដំណាំស្រូវងាប់ ប្រសិនបើការបំផ្លាញមានសភាពធ្ងន់ធ្ងរ ។ វិធីសាស្ត្រសំខាន់ៗ ដើម្បីគ្រប់គ្រងទ្រីបមានដូចជា:

- ប្រើផេះបាចលើដំណាំស្រូវដែលទទួលរងការបំផ្លាញ
- បញ្ចូលទឹកទៅក្នុងថ្នាលសំណាប ឬ យកទឹកទៅបាញ់លើស្លឹកស្រូវឱ្យជោគ
- ប្រើស្បៃមុង ឬ ក្រមា ដែលមានជាតិអំបោះ ជ្រលក់ទឹកឱ្យសើម រួចអូសលើថ្នាលចុះឡើងៗ រួចពូតសម្លាប់សត្វទ្រីប ។

***ខ. មមាចត្នោត:*** ជាសត្វល្អិតដែលស៊ីបំផ្លាញដំណាំស្រូវយ៉ាងធ្ងន់ធ្ងរ ដោយវាជញ្ជក់យករុក្ខរស ពីដើមស្រូវ និងជាភ្នាក់ងារចម្លងជំងឺតឿស្មៅ និងជំងឺតឿរួញស្លឹក។ វិធីសាស្ត្រគ្រប់គ្រងមមាចត្នោតមានដូចខាងក្រោម:

- គួរប្រើប្រាស់ពូជដែលធន់នឹងមមាចត្នោត
- ស្រែដែលព្រោះស្រូវគួរតែនៅឆ្ងាយពីផ្ទះ និងឆ្ងាយពីអំពូលភ្លើង
- គួរដាំដុះដំណាំស្រូវឱ្យបានស្របពេលគ្នា
- ធ្វើអនាម័យស្រែ (សំអាតស្មៅចង្រៃ ទាំងលើភ្លឺ និងក្នុងស្រែ)
- ប្រើប្រាស់ជីឱ្យបានសមស្រប និងមានតុល្យភាព (ចៀសវាងប្រើប្រាស់ជីអាសូតច្រើន)
- ក្នុងករណីមានមមាចត្នោតច្រើន ត្រូវពន្លិចទឹកទៅក្នុងស្រែ និងយកស្បៃមុងអូសកម្ចាត់មមាចត្នោត
- ប្រើអន្ទាក់ភ្លើងដើម្បីត្រួតពិនិត្យមមាចត្នោត និងចាត់វិធានការទាន់ពេលវេលា

- ថែរក្សាសត្វមានប្រយោជន៍ក្នុងស្រែ (ដូចជាសត្វពស់គ្មានពិស) ដើម្បីចៀសវាងការប្រើថ្នាំពុលគីមី
- ប្រើថ្នាំធម្មជាតិៈ វល្លិ៍ដង ស្លឹកគ្រៃ សំបកកន្ទួត ទំពាំង សំបកស្ដៅ លាមកមាន់ និងថ្នាំជក់ ក្នុងមួយមុខក្នុងបរិមាណ ១គីឡូក្រាម លាយជាមួយទឹក ៣០លីត្រ ត្រាំផ្អាប់វាចំនួន ៧-១០ ថ្ងៃ អាចប្រើប្រាស់បាន ។ នៅពេលយកទៅប្រើប្រាស់ទឹកថ្នាំ១លីត្រ ត្រូវលាយជាមួយទឹកធម្មតាចំនួន ៨-១០ លីត្ររួចបាញ់លើដំណាំស្រូវដែលទទួលរងការបំផ្លាញពីមមាចត្នោត ។
- ការប្រើប្រាស់ថ្នាំគីមីជាជម្រើសចុងក្រោយៈ ប្រើថ្នាំប៊ុយទីល (Butul) ដើម្បីកំចាត់កូនមមាចក្នុងករណីមានបរិមាណច្រើនក្នុងកម្រិត ៣-៤ ក្រាមលាយជាមួយទឹក ២០លីត្រ ដោយបាញ់ទឹកថ្នាំលាយនេះពី ៣៦០-៤០០ លីត្រ/ហិកតា ។

***គ. ដង្កូវបំពង់កាត់ស្លឹកៈ*** ភាគច្រើនវាស៊ីបំផ្លាញដំណាំស្រូវនៅវគ្គលូតលាស់ ឬ ចំណែកនៃស្រែដែលមានទឹកដក់ជាប្រចាំ ។ វិធានការគ្រប់គ្រងដង្កូវបំពងកាត់ស្លឹកមានដូចតទៅៈ

- បញ្ចូលទឹកទៅក្នុងស្រែឱ្យលិច រួចយកស្បៃមុងអូសយកដង្កូវទៅកំទេចចោល
- បង្ហូរទឹកចូលទៅក្នុងស្រែឱ្យបាន ២-៣ ថ្ងៃ ទើបបញ្ចូលទឹកជាថ្មី ។ ការបង្ហូរទឹកត្រូវមានឧបករណ៍សម្រាប់ត្រងដង្កូវយកទៅកំទេចចោល ។
- ប្រើផេះបាចលើស្រែដែលមានការកាត់បំផ្លាញ
- ប្រើស្លឹកស្ដៅ ឬ ស្លឹកទន្រ្ទានខែត្រ បាចក្នុងស្រែដែលមានការបំផ្លាញ
- ព្រលែងសត្វទាចូលក្នុងស្រែ ដើម្បីឱ្យវាស៊ីដង្កូវដែលអណ្ដែតលើទឹក
- ថែរក្សាសត្វមានប្រយោជន៍
- ប្រើប្រាស់ថ្នាំពុលគីមីករណីមានចំនួនសត្វល្អិតច្រើន ។

***ឃ. ដង្កូវស៊ីរូងដើមៈ*** បំផ្លាញដំណាំស្រូវចាប់ពីវគ្គលូតលាស់រហូតដល់វគ្គបង្កើនផល។ នៅវគ្គលូតលាស់វាធ្វើឱ្យស្រូវងាប់បណ្ដូល ចំណែកឯនៅវគ្គបង្កើនផល វាធ្វើឱ្យកួរស្រូវចេញមកស្កក (កួរសរ) ប៉ុន្តែ ជាទូទៅដង្កូវស៊ីរូងដើមពុំបង្កការបំផ្លាញធ្ងន់ធ្ងរ និងធ្វើឱ្យបាត់បង់ទិន្នផលខ្លាំងពេកទេ ។ វិធីសាស្រ្ត ដើម្បីគ្រប់គ្រងដង្កូវស៊ីរូងដើមមានដូចខាងក្រោមៈ

- ប្រើពូជស្រូវអាយុកាលខ្លី ពូជស្រូវធន់នឹងដង្កូវស៊ីរូងដើម
- ភ្ជួរលុបគល់ជញ្រ្ជាំងភ្លាម ក្រោយពីប្រមូលផលស្រូវរួច ដើម្បីសម្លាប់ដង្កូវ និងដឹកដឿ
- ប្រើបរិមាណជីឱ្យបានសមស្រប និងមានតុល្យភាព

- ថែរក្សាសត្វមានប្រយោជន៍នៅក្នុងស្រែ ដើម្បីឱ្យវាស៊ីសត្វល្អិតចង្រៃ
- ប្រើប្រាស់ថ្នាំពុលគីមីជាជម្រើសចុងក្រោយ ។





## ៩. ការប្រមូលផល

➢ ***តើនៅពេលណាដែលយើងគួរធ្វើការច្រូតកាត់ស្រូវ?***

ត្រូវបង្ហូរទឹកចេញពីស្រែឱ្យបានពី ៧-១០ថ្ងៃមុនពេលប្រមូលផល នៅពេលដែលយើងពិនិត្យឃើញថាស្រូវមានភាពទុំពេញលេញ ដែលបានប្តូរពណ៌ពីបៃតងទៅលឿងទុំ ហើយគ្រាប់ស្រូវមិនទុំពេក និងមិនខ្ចីពេក ហើយគួរច្រូតកាត់ស្រូវនៅសំណើមពី ២០-២៥% ។ ត្រូវពិនិត្យឱ្យឃើញថាដើមស្រូវ និងកួរស្រូវមានភាពស្ងួត និងមានភាពទុំពី ៨០-៨៥% ។ ប្រសិនបើករណី ដំណាំស្រូវមានភាពសើមខ្លាំង ដូចជានៅពេលមានភ្លៀងធ្លាក់ ឬ នៅពេលព្រឹកព្រលឹម គឺយើងគួរតែរង់ចាំឱ្យវាស្ងួតទឹកអស់សិនទើបធ្វើការច្រូតកាត់។ ការប្រមូលផលយឺតពេកបណ្តាលឱ្យគ្រាប់ស្រូវ ជ្រុះខ្ចាត់ខ្ចាយក្នុងស្រែច្រើន ឬ ស្ងួតជ្រុះធ្វើឱ្យងាយប្រេះស្រាំ នៅពេលបោកបែនហើយគ្រាប់ស្រូវអាចបាក់នៅពេលកិនជាអង្ករ ។ ការប្រមូលផលឆាប់ពេក បណ្តាលឱ្យគ្រាប់ស្រូវជាច្រើនទុំស្មើរ ដែលធ្វើឱ្យថយចុះនូវបរិមាណ និងគុណភាពអង្ករដើមដែលកិនបាន ។

ដើម្បីឱ្យការច្រូតកាត់ស្រូវធ្វើឡើងបានសមស្របបំផុត គេមិនត្រូវគិតតែអាយុកាលរបស់ដំណាំ ដែលមានការប្រែប្រួលទៅតាមប្រភេទពូជប៉ុណ្ណោះទេ ប៉ុន្តែគេក៏ត្រូវពិនិត្យមើលផងដែរនូវកម្រិតទុំជាក់ស្តែងរបស់ស្រូវ ។

 

## ១០. ការគ្រប់គ្រងគ្រោះហានិភ័យនានាចំពោះដំណាំស្រូវពង្រោះ

ការគ្រប់គ្រងគ្រោះហានិភ័យ ចំពោះដំណាំស្រូវពិតជាមានសារៈសំខាន់ខ្លាំងណាស់ មិនថាស្រូវពង្រោះ ឬស្រូវសន្ទូងនោះទេ ជាក់ស្តែងដូចស្រូវពង្រោះតែងតែមានជួបប្រទះនូវហានិភ័យមួយចំនួន ប៉ុន្តែទន្ទឹមនឹងនេះយើងត្រូវចេះគ្រប់គ្រងគ្រោះហានិភ័យទាំងនោះផងដែរ។ ខាងក្រោមនេះ ជាវិធានការមួយចំនួនសម្រាប់គ្រប់គ្រងគ្រោះហានិភ័យ៖

- ជ្រើសរើសពេលវេលាដែលសមស្របសម្រាប់ព្រោះស្រូវ
- មានប្រភពទឹកសម្រាប់ផ្គត់ផ្គង់ពេលជួបគ្រោះរាំងស្ងួត
- ជីកចង្អូរនៅក្នុងស្រែពេលមានទឹកលិច និងមានប្រឡាយមេសម្រាប់បង្ហូរទឹកចេញ
- មានសំណាបសម្រាប់ត្រៀមជួសពេលស្រូវអត់ដុះ
- ការដាក់ជីបំប៉ន ដើម្បីជំរុញការលូតលាស់របស់ដំណាំស្រូវ
- ការសំអាតស្មៅជាប្រចាំអាចធ្វើឱ្យដំណាំស្រូវដុះលូតលាស់បានល្អ

# ១១. ការធ្វើផែនការផលិតកម្ម

## ១១.១ ការកត់ត្រាចំណាយ ចំណូលផលិតកម្ម

ការកត់ត្រានូវតួរលេខចំណាយ ចំណូលពិតជាមានសារៈសំខាន់ណាស់លើផ្នែកសេដ្ឋកិច្ច ។ មានហេតុផលជាច្រើនដែលគេចាំបាច់ត្រូវកត់ត្រាជាប្រចាំពីចំណាយ ចំណូលផលិតកម្ម ។ ហេតុផលមួយចំនួនមានដូចជា:

- អាចឱ្យយើងដឹងបានថាតើផលិតកម្មរបស់យើង(ការដាំដំណាំស្រូវ) របស់យើងខាត ឬ ចំណេញ។ ចូរចងចាំថាការទទួលបានប្រាក់ចំណូល មិនមែនយើងទទួលបានប្រាក់ចំណេញនោះទេ ។
- ការដឹងច្បាស់ពីការចំណាយនិងចំណូលអាចឱ្យយើងគ្រប់គ្រងផលិតកម្មរបស់យើងបានកាន់តែល្អ និងអាចទទួលបានប្រាក់ចំណេញកាន់តែច្រើនឡើងនៅវគ្គបន្ទាប់ ។
- កំណត់ត្រាអាចប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគតពីព្រោះយើងអាចដឹងពីការចំណាយ និងធនធានដែលត្រូវប្រើប្រាស់ នៅពេលវគ្គបន្ទាប់។

គោលដៅចំបងនៃការធ្វើផលិតកម្ម គឺដើម្បីទទួលបានប្រាក់ចំណេញ និងកាន់តែចំណេញច្រើន ។ **(ប្រាក់ចំណេញជាផលសង ឬ ភាពខុសគ្នាជាវិជ្ជមាន)** រវាងប្រាក់ចំណូល (បានមកពីការលក់ផលិតផល ឬ សេវាកម្ម និងប្រាក់ចំណាយទាំងអស់) ។ ចំណាយអាចបែងចែកជា ២ ប្រភេទគឺ:

**ក. ចំណាយថេរ:** (មិនប្រែប្រួល) គឺជាចំណាយមូលធន ដែលប្រើប្រាស់មួយសារមិនអស់ ឬ មិនខូច មានដូចជា: ដី សំណាញ់ ម៉ាស៊ីនបូមទឹក ឬ កង្ហារខ្យល់ទាញទឹក ប្រព័ន្ធស្រោចស្រព រោងបណ្ដុះសំណាប ។ល។ ដែលសម្ភារទាំងអស់នេះមានតម្លៃត្រូវកាត់រំលស់ជាប្រចាំទោះបីជាមានការផលិត ឬ គ្មានការផលិតបន្តទៀតក៏ដោយ ។ ដោយសារសម្ភារ និងឧបករណ៍ក្នុងចំណាយមិនប្រែប្រួលទាំងនេះ (អាចប្រើប្រាស់បានច្រើនដង) ហើយអាចអាចប្រើក្នុងផលិតកម្មសារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វាជាច្រើនដង/ច្រើនសារ។ ការកំណត់ចំនួនសាររំលស់ថ្លៃឧបករណ៍ និងសម្ភារក្នុងប្រភេទចំណាយថេរនេះ អាចគិតបានច្រើនបែបដូចជា តាមចំនួនសារ(ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើប្រាស់វាបាន ។

**ខ. ចំណាយប្រែប្រួល:** គឺជាប្រភេទចំណាយជាក់ស្តែងសម្រាប់ផលិតកម្ម ឬ សេវាកម្មអ្វីមួយ។ ការចំណាយប្រភេទនេះរួមមានវត្ថុធាតុដើមដូចជា: គ្រាប់ពូជ ជី ថ្នាំកសិកម្ម ការរៀបចំដី ថ្លៃបូមទឹកស្រោចស្រព ពលកម្ម ដែលចាំបាច់សម្រាប់ផលិតកម្ម ។

ដើម្បីឱ្យដឹងកាន់តែច្បាស់ថា ផលិតកម្មដំណាំស្រូវសម្រេចបានលទ្ធផលយ៉ាងណានោះគេត្រូវការព័ត៌មានជាចាំបាច់ ដែលមិនអាចរកបានក្រៅពីការកត់ត្រាជាប្រចាំ និងបានត្រឹមត្រូវរបស់យើងនោះឡើយ។ ការកត់ត្រាអាចផ្តោតលើការប្រមូលព័ត៌មានជាចាំបាច់ សម្រាប់វិភាគចំណាយ ចំណេញ ខាត និងតម្រង់ទិសមុខរបរ ឬ ផលិតកម្មតាមពេលវេលាឱ្យឆ្លើយតបទៅតាមតម្រូវការហួបចុក និងលក់ទៅកាន់ទីផ្សារប្រមូលផ្តុំតាមផែនការ ឬកិច្ចសន្យាទិញ លក់ ។ ខាងក្រោមនេះជាទម្រង់កត់ត្រាគំរូសាមញ្ញមួយដែលកសិករ (អ្នកដាំដំណាំស្រូវ) អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូល ចំណេញ ខាត របស់ខ្លួន ។

## ១១.២ តារាងគំរូ សម្រាប់វិភាគចំណាយ ចំណូលផលិតកម្មដំណាំស្រូវ

### ក. តារាងចំណាយ

| ល.រ | មុខចំណាយ | ឯកត្តា | ចំនួន | តម្លៃ/ឯកត្តា | | ចំណាយសរុប | |
|---|---|---|---|---|---|---|---|
| | | | | ដុល្លា | រៀល | ដុល្លា | រៀល |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |
| **ចំណាយសរុប** | | | | | | | |

### ខ. តារាងចំណូល

| ល.រ | មុខចំណូល | ឯកត្តា | ចំនួន | តម្លៃ/ឯកត្តា | | ចំណូលសរុប | |
|---|---|---|---|---|---|---|---|
| | | | | ដុល្លា | រៀល | ដុល្លា | រៀល |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |

| ចំណាយសរុប | | |
|---|---|---|

**គ. តារាងចំណេញ/ខាតក្នុង ១ វដ្តផលិតកម្មដំណាំស្រូវ**

| |
|---|
| ប្រាក់ចំណេញ = ប្រាក់ចំណូល - ប្រាក់ចំណាយ |

| |
|---|
| ប្រាក់ចំណេញសរុប= ប្រាក់ចំណូលសរុប-ប្រាក់ចំណាយសរុប |

## ១១.៣ គំរូផលិតកម្មដំណាំស្រូវដោយផ្អែកលើការសិក្សានៃសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (សម្រាប់ផ្ទៃដី ០.៥០ហត)។ អាចមានការប្រែប្រួលទៅតាមការជាក់ស្តែង។

| ល.រ | សេចក្តីអធិប្បាយ | ឯកតា | បរិមាណ | តម្លៃរាយ | | ចំនួន | | សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | | | ដុល្លារ | រៀល | ដុល្លារ | រៀល | |
| 1. | ពូជផ្ការំដួល | គ.ក្រ | 30 | 0.80 | 3,200 | 24 | 96,000 | |
| 2. | ជីធម្មជាតិ | គ.ក្រ | 150 | 0.371 | 1,484 | 55.65 | 222,600 | |
| 3. | ជី (15 15 15) | គ.ក្រ | 25 | 0.625 | 2,500 | 15.625 | 62,500 | |
| 4. | អ៊ុយរ៉េ (Urea) | គ.ក្រ | 25 | 0.55 | 2,200 | 13.75 | 55,000 | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5. | ថ្នាំសម្លាប់សត្វល្អិត (Oshin) | កញ្ចប់ | 10 | 0.625 | 2,500 | 6.25 | 25,000 | |
| 6. | ថ្នាំ Sunrus 100PW (destroy weed) | កញ្ចប់ | 4 | 3.25 | 13,000 | 13 | 52,000 | |
| 7. | ចប | សរុប | 1 | | | | | |
| 8. | ផ្សេងៗ | | | | | | | |
| សរុបរង | | | | | | **128.275** | **513,100** | |
| តម្លៃមិនបានគិតទុកមុន **(5%)** | | | | | | **6.41375** | **25,655** | |
| សរុប ១ | | | | | | **134.68875** | **538,755** | |
| Operational cost | | | | | | | | |
| 9. | ប្រេង | លីត្រ | 7.5 | 1.25 | 5,000 | 9.375 | 37,500 | |
| 10. | តម្លៃរៀបចំដី | សរុប | 1 | 18.75 | 75,000 | 18.75 | 75,000 | |
| 11. | តម្លៃច្រូតកាត់ | សរុប | 1 | 35 | 140,000 | 35 | 140,000 | |
| 12. | តម្លៃដឹកជញ្ជូន | សរុប | 1 | 5 | 20,000 | 5 | 20,000 | |
| 13. | ពលកម្ម | សរុប | 2 | 30 | | | | |
| សរុប ២ | | | | | | **68.125** | **272,500** | |
| សរុប **1+2 (**តម្លៃផលិតកម្មកន្លះហិចតា **0.5Ha** គិតជាមធ្យម**)** | | | | | | **202.81375** | **811,255** | |
| តម្លៃផលិតកម្មមួយហិចតា (**1Ha**) គិតជាមធ្យ | | | | | | *405.6275* | *1,622,510* | |

## អ្នកចូលរួមពិភាក្សា កែសម្រួល និងរៀបចំសៀវភៅបច្ចេកទេស

- លោក **សុខ សុថា** ប្រធានស្ថាបនិកនិងជាប្រធានប្រតិបត្តិ សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (**CFAP-CAMBODIA**)
- កញ្ញា **នូ សារស់** មន្ត្រីកសិកម្មនៃសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
- លោក លោកស្រី បុគ្គលិក ទីប្រឹក្សាសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម។